ធនាគារជាតិ នៃ កម្ពុជា

លេខ........................................................

# សុន្ទរកថា
# ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងឱកាសបើកសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៥
# និងទិសដៅការងារឆ្នាំ២០១៦ របស់ធនាគារជាតិនៃកម្ពុជា

**នៅសាលសន្និសីទចតុមុខ ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៦**

**សូមគោរព :**

- **គណៈអធិបតី**
- **លោក Hervé Dallarac ជំនាញការទូទៅប្រចាំធនាគារជាតិនៃកម្ពុជា!**
- **លោក Robert Beerens ជំនាញការប្រចាំធនាគារជាតិនៃកម្ពុជា!**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ជាទីមេត្រី!**

១- ថ្ងៃនេះ ខ្ញុំមានក្តីសោមនស្សរីករាយជាអនេកប្បការ ដែលបានចូលរួមក្នុងសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៥ និងទិសដៅការងារឆ្នាំ២០១៦ របស់ធនាគារជាតិនៃកម្ពុជា ។ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ដែលមានវត្តមាននៅក្នុងសន្និបាតនាពេលនេះ ដែលមានចំនួនច្រើនជាងឆ្នាំមុន គឺមានចំនួនប្រមាណជិតពាក់កណ្តាលនៃមន្ត្រីបុគ្គលិកទាំងអស់ ។ ការអញ្ជើញមន្ត្រីបុគ្គលិកឱ្យចូលរួមកាន់តែច្រើននេះ គឺក្នុងស្មារតីផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយ និងដើម្បីអបអរសាទរលទ្ធផលការងារដែលធនាគារជាតិនៃកម្ពុជាសម្រេចបាននៅឆ្នាំកន្លងទៅ ព្រមទាំងទស្សនវិស័យនិងទិសដៅការងារនៅឆ្នាំ២០១៦ នេះ សម្រាប់សម្រេចបានជោគជ័យថ្មីៗបន្ថែមទៀត ។

២- សន្និបាតរបស់យើងនាពេលនេះ ត្រូវបានរៀបចំឡើងក្រោយពេលដែលប្រជាជនខ្មែរទូទាំងប្រទេសបានប្រារព្ធទិវាមហាជ័យជំនះ ៧ មករា លើកទី៣៧ ជាថ្ងៃដែលប្រជាជនយើងរួចផុតពីក្រញាំនៃរបបប៉ុល ពត និងបានចាប់ផ្តើមធ្វើការអភិវឌ្ឍនៅលើគ្រប់វិស័យពីបាតដៃទទេ រហូតដល់មានការរីកចម្រើនដូចសព្វថ្ងៃ ។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណ និងកោតសរសើរយ៉ាងខ្លាំងចំពោះមន្ត្រីបុគ្គលិកគ្រប់ថ្នាក់ដែលបានខិតខំប្រឹងប្រែងបំពេញមុខងារភារកិច្ចប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងសម្រេចបានសមិទ្ធផលជូនធនាគារជាតិនៃកម្ពុជា នារយៈកន្លងមក ។

**លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី**

៣- នៅឆ្នាំ២០១៥ នេះ ទោះបីជាកំណើនសេដ្ឋកិច្ចពិភពលោកនៅបន្តងើបឡើងដោយមិនស្មើសាច់និងមានល្បឿនយឺតជាងឆ្នាំកន្លងទៅក៏ដោយ សេដ្ឋកិច្ចកម្ពុជានៅបន្តរក្សាបានកំណើនខ្ពស់រឹងមាំ ។ នៅក្នុងប្រទេសអភិវឌ្ឍន៍ សេដ្ឋកិច្ចសហរដ្ឋអាមេរិកបានកើនឡើងយ៉ាងរឹងមាំ ខណៈដែលសេដ្ឋកិច្ចតំបន់អឺរ៉ូនិងជប៉ុនបន្តមានកំណើនទន់ខ្សោយនៅឡើយ ។ ចំណែកឯកំណើនសេដ្ឋកិច្ចប្រទេសកំពុងងើបឡើងនិងប្រទេសកំពុងអភិវឌ្ឍន៍បានបន្តថយចុះក្នុងរយៈពេល ៥ឆ្នាំ ជាប់គ្នា ។ ការបន្តទទួលបានកំណើនយឺតគួបផ្សំនឹងភាពស្ថិតក្នុងការប្រែប្រួលនៃគោលនយោបាយក្នុងសេដ្ឋកិច្ចធំៗមួយចំនួន បានធ្វើឱ្យសេដ្ឋកិច្ចពិភពលោកនៅពុំទាន់មានភាពច្បាស់លាស់នៅឡើយ ហើយបន្តប្រឈមនឹងហានិភ័យដែលអាចទាញឱ្យសេដ្ឋកិច្ចថយចុះនាពេលខាងមុខ ។ សេដ្ឋកិច្ចដែលគោលនយោបាយស្ថិតក្នុងអន្តរកាលរួមមាន ៖ សហរដ្ឋអាមេរិកអាចនឹងបន្តបង្កើនអត្រាការប្រាក់របស់ខ្លួន បន្ទាប់ពីសេដ្ឋកិច្ចបានងើបឡើងជាលំដាប់ ដែលបញ្ហានេះអាចធ្វើឱ្យមានការប្រែប្រួលខ្លាំងនៃលំហូរទុននៅក្នុងទីផ្សារហិរញ្ញវត្ថុ និងការហូរទុនចេញពីប្រទេសកំពុងងើបឡើង ចំណែកឯសេដ្ឋកិច្ចចិនមានល្បឿនកំណើនថយចុះជាលំដាប់ ដោយសារការកែសម្រួលរចនាសម្ព័ន្ធសេដ្ឋកិច្ចទៅរកការពឹងផ្អែកលើមូលដ្ឋានក្នុងស្រុក ដែលការធ្លាក់ចុះនឹងអាចមានឥទ្ធិពលរាលដាលទៅដល់តំបន់នានាលើសកលលោក ។

៤- ប្រឈមនឹងស្ថានភាពខាងលើ ការពង្រឹងមូលដ្ឋានសេដ្ឋកិច្ចនៅក្នុងតំបន់មានសារៈសំខាន់ណាស់ ដើម្បីលើកកម្ពស់សហថាមភាព និងភាពធន់នឹងវដ្តនៃសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសកល សំដៅរក្សាបាននូវកំណើនប្រកបដោយចីរភាព ។ នៅចុងឆ្នាំ២០១៥ នេះ ប្រជាជាតិនៃសមាគមអាស៊ីអាគ្នេយ៍ (អាស៊ាន) បានសម្រេចចាប់ផ្តើមអនុវត្តដំណើរការសហគមន៍សេដ្ឋកិច្ចអាស៊ានជាផ្លូវការតាមការគ្រោងទុក ។ ស្ថិតក្នុងតំបន់ដែលមានសេដ្ឋកិច្ចកាន់តែសមាហរណកម្មនិងសកម្ម កម្ពុជាបានពង្រឹងខ្លួនជាលំដាប់ តាមរយៈការអនុវត្តកម្មវិធីកំណែទម្រង់ស៊ីជម្រៅ និងគោលនយោបាយសេដ្ឋកិច្ចចម្បងៗប្រកបដោយទស្សនវិស័យវែងឆ្ងាយដើម្បីដោះស្រាយបញ្ហាចំពោះមុខ និងទាញយកអំណោយផលពីសមាហរណកម្មតំបន់ ។ ផ្លែផ្កានៃការអនុវត្តគោលនយោបាយទាំងនេះ បានធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាសម្រេចបានកំណើន ៦,៩% នៅឆ្នាំ២០១៥ ដែលគាំទ្រដោយកំណើននៃការនាំចេញផលិតផលវាយនភ័ណ្ឌ ការធ្លាក់ចុះនៃថ្លៃប្រេង និងកំណើនតម្រូវការក្នុងស្រុក ជាពិសេស ក្នុងវិស័យសំណង់ អចលនទ្រព្យ និងការប្រើប្រាស់ ។

៥- ការបន្តរក្សាបាននូវអត្រាកំណើនខ្ពស់នេះ បានធ្វើឱ្យឆ្នាំ២០១៥ ក៏ជាឆ្នាំដែលកម្ពុជាបានត្រៀមខ្លួនរួចរាល់ក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាបនៅឆ្នាំ២០១៦

នេះ ។ សមិទ្ធផលដ៏ថ្លៃថ្លាដែលមានអត្ថន័យជាប្រវត្តិសាស្ត្រនេះ ប្រសូត្រចេញពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការធានាបាននូវសុខសន្តិភាព ស្ថិរភាពនយោបាយ និងភាពជោគជ័យនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិជាបន្តបន្ទាប់ ។ នៅក្នុងរយៈពេលខ្លីនិងមធ្យម សេដ្ឋកិច្ចកម្ពុជារំពឹងថានឹងទទួលបានកំណើនរឹងមាំបន្តទៀត ទោះបីជាប្រឈមនឹងហានិភ័យមួយចំនួនដូចជា ៖ i- ការប៉ះពាល់ដល់ភាពប្រកួតប្រជែងដែលបណ្តាលមកពីការឡើងថ្លៃនៃប្រាក់ដុល្លារអាមេរិក, ការកើនឡើងថ្លៃឈ្នួលកម្លាំងពលកម្មក្នុងវិស័យកាត់ដេរ, និងការកើនឡើងនៃដៃគូប្រកួតប្រជែងក្នុងតំបន់ រួមមានការបង្កើតតំបន់ពាណិជ្ជកម្មអន្តរប៉ាស៊ីហ្វិក (TPP) និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងវៀតណាមនិងតំបន់អឺរ៉ូ, និងការបើកចំហសេដ្ឋកិច្ចរបស់ប្រទេសមីយ៉ាន់ម៉ា, ii- ឥទ្ធិពលនៃការធ្លាក់ចុះសេដ្ឋកិច្ចចិននិងកំណើនទន់ខ្សោយនៃសេដ្ឋកិច្ចតំបន់អឺរ៉ូ និង iii- លំហូរទុនចេញពីតំបន់និងស្ថានភាពរឹតត្បិតនៃទីផ្សារហិរញ្ញវត្ថុ ។

៦- នៅឆ្នាំ២០១៥ នេះ ក៏ដូចជានារយៈពេលកន្លងមក ខ្ញុំមានសេចក្តីរីករាយជាអតិបរមាដែលធនាគារជាតិនៃកម្ពុជាយើងបានបន្តរួមចំណែក ក្នុងការសម្រេចបាននូវគោលដៅចម្បងៗរបស់រាជរដ្ឋាភិបាល គឺ កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ តាមរយៈការរួមចំណែករក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ស្ថិរភាពហិរញ្ញវត្ថុ និងបរិយាប័ន្នហិរញ្ញវត្ថុ ។ ការរួមចំណែកទាំងនេះ ត្រូវបានធ្វើឡើងតាមរយៈការអនុវត្តមុខងារ-ភារកិច្ចប្រកបដោយប្រសិទ្ធភាពរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការរក្សាបាននូវស្ថិរភាពថ្លៃនិងតម្លៃប្រាក់រៀល, ការអភិវឌ្ឍវិស័យធនាគារនិងហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ, ការជំរុញសមាហរណកម្មវិស័យហិរញ្ញវត្ថុក្នុងតំបន់, និងការពង្រឹងបណ្តាញសុវត្ថិភាពហិរញ្ញវត្ថុតំបន់ ។

៧- ថ្លៃគឺជាកត្តាមូលដ្ឋានមួយនៃការសម្រេចចិត្តទាំងក្នុងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ ការរក្សាបានស្ថិរភាពថ្លៃ គឺបានធ្វើឱ្យការសម្រេចចិត្តមានភាពច្បាស់លាស់ក្នុងការវិនិយោគនិងផលិតកម្ម ។ ដូច្នេះ ស្ថិរភាពថ្លៃរួមចំណែកជាចម្បងរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចដែលបង្កើតបរិស្ថានអំណោយផលដល់ការជំរុញសកម្មភាពសេដ្ឋកិច្ច ដែលគាំទ្រដល់កំណើននិងការបង្កើតការងារ ។ នៅឆ្នាំ២០១៥នេះ អត្រាអតិផរណាមានកម្រិត ១,២% ទាបជាងឆ្នាំកន្លងទៅ ដែលបង្ហាញថា ស្ថិរភាពថ្លៃត្រូវរក្សាបានកាន់តែល្អប្រសើរ ។ ការរក្សាបានស្ថិរភាពថ្លៃនេះ គឺដោយសារការអនុវត្តគោលនយោបាយរូបិយវត្ថុប្រកបដោយការប្រុងប្រយ័ត្ន ដោយថ្លឹងថ្លែងពីបរិមាណសន្ទនីយភាពគ្រប់គ្រាន់សម្រាប់គាំទ្រការរីកចម្រើនសកម្មភាពសេដ្ឋកិច្ចនិងការគ្រប់គ្រងសម្ពាធអតិផរណា, ស្ថិរភាពតម្លៃប្រាក់រៀល និងកត្តាអំណោយផលពីខាងក្រៅ រួមមានសម្ពាធទាបនៃអតិផរណានាំចូល និងការធ្លាក់ចុះនៃថ្លៃ

ប្រេងពិភពលោក ។ នៅក្នុងស្ថានភាពដែលការផ្គត់ផ្គង់ប្រេងត្រូវបានព្យាករថានឹងមានបរិមាណថេរ ហើយតម្រូវការប្រេងបន្តមានភាពទន់ខ្សោយ ថ្លៃប្រេងត្រូវបានរំពឹងថានឹងបន្តស្ថិតក្នុងកម្រិតទាបនៅឆ្នាំ២០១៦ ដែលនឹងរួមចំណែកបន្ទាបអត្រាអតិផរណាតំបន់និងកម្ពុជា ។

៨- ក្នុងឆ្នាំនេះ រូបិយប័ណ្ណក្នុងតំបន់បានធ្លាក់ថ្លៃគួរឱ្យកត់សម្គាល់ធៀបនឹងដុល្លារអាមេរិកជាពិសេស ប្រាក់បាតថៃ ប្រាក់រីងហ្គីតម៉ាឡេស៊ី ប្រាក់ដុងវៀតណាម ជាដើម បន្ទាប់ពីការងើបឡើងជាបន្តបន្ទាប់នៃសេដ្ឋកិច្ចសហរដ្ឋអាមេរិក និងការប៉ាន់ស្មានលើការបង្កើនជាលំដាប់នៃអត្រាការប្រាក់របស់ធនាគារកណ្តាលអាមេរិក ដែលបានធ្វើឱ្យមូលធនហូរចេញពីតំបន់ ។ ការធ្លាក់ថ្លៃនៃរូបប័ណ្ណទាំងនេះ ក៏បានបង្កជាសម្ពាធធ្វើឱ្យប្រាក់រៀលថយថ្លៃធៀបនឹងប្រាក់ដុល្លារអាមេរិកផងដែរ ។ ជាការឆ្លើយតប ធនាគារជាតិនៃកម្ពុជាបានធ្វើអន្តរាគមន៍ដោយប្រុងប្រយ័ត្ននៅលើទីផ្សារប្តូរប្រាក់ ដើម្បីគ្រប់គ្រងអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកឱ្យមានស្ថិរភាពបានយ៉ាងល្អប្រសើរ ។ ការរក្សាបាននូវស្ថិរភាពតម្លៃប្រាក់រៀលក្នុងបរិយាកាសនេះ បានបង្ហាញពីប្រសិទ្ធភាពនៃគោលនយោបាយប្តូរប្រាក់របស់ធនាគារជាតិនៃកម្ពុជា សម្រាប់ការពារអំណាចទិញរបស់ប្រជាជនដែលទទួលបានចំណូលជាប្រាក់រៀលប៉ុណ្ណោះទេ ក៏ដូចជាបង្កើនជំនឿទុកចិត្តរបស់សាធារណជនមកលើប្រាក់រៀលឱ្យបានតែរឹងមាំ ។ គួរបញ្ជាក់ផងដែរថា ស្ថិរភាពអត្រាប្តូរប្រាក់បានដើរតួនាទីចាំបាច់ប្រៀបបានដូចជាយុថ្កា ថែរក្សាស្ថិរភាពថ្លៃនៅកម្ពុជាដូច្នេះដែរ ។

៩- ការប្រើប្រាស់រូបិយវត្ថុជាតិឱ្យបានទូលំទូលាយនៅក្នុងសេដ្ឋកិច្ច គឺជាកត្តាចាំបាច់បំផុតក្នុងការបង្កើនប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ ។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជាបានគាំទ្រនិងចូលរួមអនុវត្តគោលនយោបាយលើកកម្ពស់ប្រាក់រៀលរបស់រាជរដ្ឋាភិបាលដែលធ្វើឡើងដោយប្រុងប្រយ័ត្ននិងផ្អែកលើយន្តការទីផ្សារ តាមរយៈការដាក់ចេញនូវវិធានការលើកទឹកចិត្តការប្រើប្រាស់ប្រាក់រៀល, ពង្រឹងការគ្រប់គ្រងចរាចរណ៍រូបិយវត្ថុនៅទូទាំងប្រទេស, លើកកម្ពស់គុណភាពនិងសុវត្ថិភាពធនបត្រ, និងបង្កើនការយល់ដឹងរបស់សាធារណជនពីសារៈសំខាន់របស់ប្រាក់រៀល ។ ជារួម កិច្ចខិតខំប្រឹងប្រែងទាំងនេះបានបង្កើនតម្រូវការប្រាក់រៀលក្នុងសេដ្ឋកិច្ចជាលំដាប់ ។ ទោះជាយ៉ាងណាក្តី បរិមាណប្រាក់រៀលក្នុងចរាចរណ៍និងប្រាក់បញ្ញើជារៀលនៅមានកម្រិតទាបនៅឡើយ ធៀបនឹងដុល្លារអាមេរិកនៅក្នុងសមាសភាគនៃរូបិយវត្ថុទូទៅ ដែលបញ្ហានេះទាមទារឱ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់បន្តរួមចំណែកឱ្យកាន់តែខ្លាំងក្នុងការជំរុញការប្រើប្រាស់ប្រាក់រៀល ។

១០- ស្របពេលដែលតម្រូវការប្រាក់រៀលបានកើនឡើង ធនាគារជាតិនៃកម្ពុជាបានបន្តស្រូបយកប្រាក់ដុល្លារអាមេរិកចូលក្នុងប្រព័ន្ធធនាគារជាលំដាប់ សំដៅរក្សាស្ថិរភាពអត្រា

ប្តូរប្រាក់ និងបានគរពូនទុនបម្រុងអន្តរជាតិឱ្យមានកម្រិតខ្ពស់សមស្រប ដែលបម្រើដល់ការអនុវត្តគោលនយោបាយរូបិយវត្ថុ និងពង្រឹងជំនឿទុកចិត្តរបស់វិនិយោគិនមកលើភាពរឹងមាំនៃសេដ្ឋកិច្ចកម្ពុជា ។ ក្នុងនាមជាស្ថាប័នគ្រប់គ្រងទុនបម្រុងអន្តរជាតិដែលជាទ្រព្យសម្បត្តិជាតិ ធនាគារជាតិនៃកម្ពុជាបានធ្វើការវិនិយោគទុនបម្រុងនេះដោយភាពប្រុងប្រយ័ត្នបំផុត ហើយបែងចែកជាសំពៀតវិនិយោគនិងសមាសភាគវិនិយោគរូបិយប័ណ្ណសំខាន់ៗ ដើម្បីគ្រប់គ្រងហានិភ័យឱ្យមានប្រសិទ្ធភាព ។ គួរកត់សម្គាល់ផងដែរថា នាពេលថ្មីៗនេះ មូលនិធិរូបិយវត្ថុអន្តរជាតិបានសម្រេចដាក់បញ្ចូលប្រាក់យ៉ន់ចិន (RMB) ទៅក្នុងកន្ត្រក SDR ហើយនិងចាប់ផ្តើមអនុវត្តនាចុងឆ្នាំ២០១៦នេះ ។ ការបញ្ចូលនេះនឹងផ្តល់លទ្ធភាពឱ្យធនាគារជាតិនៃកម្ពុជា ក៏ដូចជាធនាគារកណ្តាលនានា អាចបង្កើនការធ្វើពិពិធកម្មទុនបម្រុងអន្តរជាតិ ដើម្បីគ្រប់គ្រងហានិភ័យអត្រាប្តូរប្រាក់បានកាន់តែប្រសើរ ។

១១- ចំពោះការអភិវឌ្ឍវិស័យធនាគារវិញ ផ្អែកលើគោលនយោបាយអភិវឌ្ឍវិស័យហិរញ្ញវត្ថុច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ វិស័យធនាគារបានបន្តរីកចម្រើនយ៉ាងឆាប់រហ័ស មានលក្ខណៈប្រកួតប្រជែង ប្រសិទ្ធភាព និងសមាហរណកម្មខ្ពស់ទៅក្នុងតំបន់និងពិភពលោក និងបានដើរតួនាទីស្នូលក្នុងការជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនិងបរិយាប័ន្ន ។ ក្របខ័ណ្ឌបទប្បញ្ញត្តិនិងត្រួតពិនិត្យត្រូវបានពង្រឹងជាបន្តបន្ទាប់ ស្របតាមស្តង់ដារអន្តរជាតិ ដើម្បីរក្សាឱ្យបានភាពរឹងមាំនិងសុវត្ថិភាពប្រព័ន្ធធនាគារ ។ ទន្ទឹមនេះ ហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុក៏ត្រូវបានអភិវឌ្ឍកាន់តែប្រសើរ ក្នុងនោះរួមមាន ៖ ការអភិវឌ្ឍទីផ្សារអន្តរធនាគារតាមរយៈការជំរុញតម្រូវការមូលបត្រអាចជួញដូរបាន ដើម្បីពង្រឹងការគ្រប់គ្រងសន្ទនីយភាពឱ្យបានល្អ, ការអភិវឌ្ឍប្រព័ន្ធទូទាត់សម្រាប់សម្រួលដល់ការទូទាត់ឱ្យកាន់តែមានសុវត្ថិភាព និងប្រសិទ្ធភាព ហើយដែលនឹងអាចទទួលបានមូលនិធិភ្លាមៗ និងធ្វើការទូទាត់អន្តរ-ធនាគារ ។ ម៉្យាងទៀត ក្នុងពេលដែលវិស័យធនាគារបានរីកចម្រើនយ៉ាងឆាប់រហ័ស អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបាននិងកំពុងពង្រឹងសមត្ថភាពវិភាគ និងតាមដានប្រតិបត្តិការសង្ស័យរបស់បុគ្គលរាយការណ៍ ដើម្បីធានាថាវិស័យធនាគារកម្ពុជាគេចផុតពីគោលដៅនៃការធ្វើសកម្មភាពសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។ ប្រសិទ្ធភាពនៃការងារនេះត្រូវបានទទួលការវាយតម្លៃខ្ពស់ដោយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ។

១២- ដើម្បីគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការសម្រេចកាត់បន្ថយភាពក្រីក្រឱ្យបានលើសពី ១% ក្នុងមួយឆ្នាំ ព្រមទាំងស្របតាមគំនិតផ្តួចផ្តើមថ្មីរបស់អាស៊ានក្រោយឆ្នាំ២០១៥ និងគោលដៅសហស្សវត្សរ៍ថ្មីរបស់អង្គការសហប្រជាជាតិ ចាប់ពីដើមឆ្នាំ២០១៥នេះ ដែលមានគោលដៅសម្រេចបានកំណើនប្រកបដោយបរិយាប័ន្ន ធនាគារជាតិនៃកម្ពុជាបានបន្តអនុវត្តគោលនយោបាយជំរុញបរិយាប័ន្នហិរញ្ញវត្ថុ ដែលសំដៅបង្កើនការប្រើប្រាស់

សេវាហិរញ្ញវត្ថុផ្លូវការកាន់តែទូលំទូលាយនិងមានតម្លៃសមរម្យ ។ បច្ចុប្បន្ននេះ ប្រជាជនពេញវ័យដែលបាននិងកំពុងប្រើប្រាស់សេវាហិរញ្ញវត្ថុ មានបរិមាណស្មើនឹងពាក់កណ្ដាលនៃប្រជាជនពេញវ័យសរុប គឺបានកើនឡើងពីកម្រិតទាប (ក្រោម ១០%) ធៀបនឹងមួយទសវត្សរ៍កន្លងទៅ ។

១៣- ការរីកចម្រើននៃវិស័យសេដ្ឋកិច្ចនិងធនាគារ និងកំណើនប្រជាជនពេញវ័យជាលំដាប់បានជំរុញឥណទានកើនឡើងយ៉ាងឆាប់រហ័ស ជាពិសេសទៅលើវិស័យសំណង់និងអចលនទ្រព្យនិងវិស័យផលិតកម្ម ។ ក្នុងបរិការណ៍នេះ គួបផ្សំនឹងបញ្ហាប្រឈមនឹងហានិភ័យនៃការប្រែប្រួលក្នុងទីផ្សារហិរញ្ញវត្ថុអន្តរជាតិ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យអនុវត្តនូវវិធានការម៉ាក្រូប្រុងប្រយ័ត្នបុរេសកម្មចម្បងៗជាបន្តបន្ទាប់ ដើម្បីគ្រប់គ្រងហានិភ័យឱ្យបានទាន់ពេលវេលានិងមានប្រសិទ្ធភាព ដូចជាការពង្រឹងស្ថានភាពសន្ទនីយភាពនិងដើមទុននិងការដាក់ប្រាក់បម្រុងកាតព្វកិច្ចលើកម្ចីអនិវាសជនជាដើម ព្រមទាំងកំពុងសិក្សាវិធានដទៃទៀតចាំបាច់សម្រាប់ពង្រឹងស្ថិរភាពហិរញ្ញវត្ថុឱ្យបានរឹងមាំ ។ ទន្ទឹមនេះ ប្រព័ន្ធចែករំលែកព័ត៌មានឥណទានក៏ត្រូវបានពង្រឹង ដើម្បីបង្កើនតម្លាភាពនិងរួមចំណែកកាត់បន្ថយហានិភ័យឥណទានក្នុងវិស័យធនាគារ ។ម្យ៉ាងទៀត គណៈកម្មាធិការស្ថិរភាពហិរញ្ញវត្ថុដែលធនាគារជាតិនៃកម្ពុជាបានបង្កើតឡើងតាំងពីឆ្នាំ២០១១ មក បានតាមដាននិងវាយតម្លៃជាប្រចាំក្នុងកម្រិតម៉ាក្រូ លើហានិភ័យនានាដែលអាចមានផលប៉ះពាល់ដល់ស្ថិរភាពហិរញ្ញវត្ថុកម្ពុជា ។

១៤- ការអភិវឌ្ឍសមត្ថភាពធនធានមនុស្សជាការងារមូលដ្ឋាននិងយុទ្ធសាស្ត្រដ៏សំខាន់របស់ធនាគារជាតិនៃកម្ពុជា ដើម្បីបង្កើនប្រសិទ្ធភាពការងារនិងជំនឿទុកចិត្តសាធារណជនមកលើវិស័យធនាគារកម្ពុជា ក្នុងស្ថានភាពដែលទំហំវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកំពុងរីកចម្រើនឥតឈប់ឈរ ហើយសេដ្ឋកិច្ចពិភពលោកមានការផ្លាស់ប្ដូរនិងសមាហរណកម្មខ្ពស់ ។ ធនាគារជាតិនៃកម្ពុជាបានពង្រឹងនិងអភិវឌ្ឍសមត្ថភាពមន្ត្រីបុគ្គលិកជាបន្តបន្ទាប់តាមរយៈវគ្គបណ្ដុះបណ្ដាលទាំងក្នុងនិងក្រៅប្រទេស ហើយបច្ចុប្បន្ន ការគរពូននិងផ្ទេរចំណេះដឹងផ្ទៃក្នុងលើជំនាញចម្បងៗក៏ត្រូវបានលើកកម្ពស់ជាប្រចាំ ។

១៥- កិច្ចខិតខំរួមគ្នា ការសម្របសម្រួល និងការដោះស្រាយបញ្ហាប្រឈម ត្រូវបានទទួលស្គាល់ថា ជាកត្តាគន្លឹះមួយក្នុងការរក្សាបាននូវកំណើននិងការអភិវឌ្ឍ ជាពិសេសចំពោះសេដ្ឋកិច្ចដែលមានទំហំតូចនិងបើកចំហដូចកម្ពុជា ។ ផ្អែកលើស្មារតីនេះ ធនាគារជាតិនៃកម្ពុជាបានពង្រឹងនិងពង្រីកជាប្រចាំ នូវកិច្ចសហប្រតិបត្តិការអន្តរជាតិល្អជាមួយភាគីពាក់ព័ន្ធនានា ក្នុងគោលបំណងទទួលបានជំនួយបច្ចេកទេស ការកសាងសមត្ថភាព និងការផ្លាស់ប្ដូរព័ត៌មាននិងបទពិសោធន៍ដែលមានសារៈប្រយោជន៍ចំពោះការងារធនាគារកណ្ដាល ព្រមទាំងពង្រឹងសមាហរណកម្មនិងបណ្ដាញសុវត្ថិភាពហិរញ្ញវត្ថុតំបន់ ។

១៦- ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងចូលរួមគាំទ្រនិងសហការជាមួយរាជរដ្ឋាភិបាល ក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ, ការគ្រប់គ្រងគម្រោងហិរញ្ញប្បទាន, យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមឆ្នាំ២០១៤-២០១៨ និងយុទ្ធសាស្ត្រអភិវឌ្ឍវិស័យឧស្សាហកម្មឆ្នាំ២០១៥-២០២៥ ។ ធនាគារជាតិនៃកម្ពុជាបានពង្រឹងគុណភាពទិន្នន័យលើស្ថិតិរូបិយវត្ថុ ជញ្ជីងទូទាត់ និងវិស័យធនាគារ ព្រមទាំងការស្រាវជ្រាវដើម្បីផ្តល់ជាមូលដ្ឋានក្នុងការតាមដានស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្ពុជា ដែលជាធាតុចូលក្នុងការរៀបចំគម្រោងអាជីវកម្ម វិនិយោគ និងផែនការអភិវឌ្ឍផ្សេងៗរបស់វិស័យឯកជននិងសាធារណៈ ឱ្យបានកាន់តែសុក្រឹតនិងជោគជ័យ ។ ទិន្នន័យនិងឯកសារទាំងនេះបានដាក់លើគេហទំព័ររបស់ធនាគារជាតិនៃកម្ពុជា ដែលអនុញ្ញាតឱ្យសាធារណជនអាចទាញយកទៅប្រើប្រាស់បានយ៉ាងងាយស្រួលនិងឆាប់រហ័ស ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី**

១៧- ដើម្បីជ្រាបពីសមិទ្ធផលលម្អិតដែលធនាគារជាតិនៃកម្ពុជាយើងសម្រេចបាន និងទិសដៅការងារសំខាន់ៗ ខ្ញុំសូមអង្គសន្និបាតមេត្តាត្រងត្រាប់ស្តាប់បទឧទ្ទេសនាមរបស់ថ្នាក់ដឹកនាំរបស់យើង ដែលនឹងរាយការណ៍ជូនអង្គសន្និបាតក្នុងរយៈពេលពីរថ្ងៃនេះ ។ ខ្ញុំសង្ឃឹមថា ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា នឹងបានយល់ច្បាស់លើខ្លឹមសារនៃអង្គសន្និបាទនេះ ព្រមទាំងយកទៅផ្សព្វផ្សាយបន្តនិងអនុវត្តក្នុងការងាររបស់ខ្លួន ឱ្យបានជោគជ័យនិងមានប្រសិទ្ធភាព ។

១៨- ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណជាភិយ្យោភាព ចំពោះក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា និងមន្ត្រីបុគ្គលិកគ្រប់ជាន់ថ្នាក់របស់ធនាគារជាតិនៃកម្ពុជា ដែលបានខិតខំប្រឹងប្រែងក្នុងការបំពេញមុខងារ-ភារកិច្ច ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីសម្រេចបានសមិទ្ធផលដ៏ប្រសើរជាបន្តបន្ទាប់នារយៈពេលកន្លងមក ។ ខ្ញុំក៏សូមថ្លែងអំណរគុណជាអនេកចំពោះគ្រប់ក្រសួង-ស្ថាប័ននានា នៅក្នុងវិស័យសាធារណៈនិងឯកជន ព្រមទាំងដៃគូអភិវឌ្ឍន៍ទាំងអស់ដែលបានគាំទ្រនិងរួមចំណែកនៅក្នុងសមិទ្ធផលនេះ ។

១៩- ជាបរិយោសាន ខ្ញុំសូមជូនពរដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី និង នាងកញ្ញា ឱ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀង ឃ្លាតឡើយ ។ ខ្ញុំសូមឱ្យអង្គសន្និបាតរបស់យើងប្រព្រឹត្តទៅប្រកបដោយជោគជ័យនិងផ្លែផ្កា ។

**ខ្ញុំសូមប្រកាសបើកអង្គសន្និបាតជាផ្លូវការចាប់ពីពេលនេះតទៅ ។**

**សូមអរគុណ!**